# ជីវិត life

ព្រឹត្តិបត្រ ព័ត៌មានពីព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លេខ ១៤ សម្រាប់ ថ្ងៃទី០១-៣០ ខែមេសា ឆ្នាំ២០១៣

## ធាតុរបស់សន្តីតេរេសា បានមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃទី២៦ មេសា ២០១៣









# លោកអភិបាល អ៊ីវ រ៉ាមូស្ស
# ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ និងជាទីស្រឡាញ់!

អ្នកស្គាល់លោក លោកក៏នាំឲ្យស្គាល់ប្រវត្តិសាស្ត្រប្រទេសកម្ពុជាយ៉ាងពិសេស ក្នុងរយៈពេល៦០ឆ្នាំកន្លងមក លោកក៏នាំឲ្យស្គាល់ប្រវត្តិសាស្ត្រព្រះសហគមន៍នៅប្រទេសកម្ពុជា និងប្រជាជនកម្ពុជាយ៉ាងពិសេសដែរ។

អ្នកជួបលោក លោកក៏ចែករំលែកបែបកក់ក្ដៅនូវអំណរសប្បាយរបស់លោក ដែលបម្រើព្រះសហគមន៍និងប្រជាជន តាមសេចក្ដីសង្ឃឹមនិងទុក្ខលំបាករបស់គេ។

អ្នកសន្ទនាជាមួយលោក ក៏ពិតជាបានទទួលនូវយោបល់ថ្មីប្រកបដោយប្រាជ្ញាវាងវៃ ជាប្រាជ្ញាដែលលោកបានសន្សំទុកមកតាមដំណើរអាយុជីវិតរបស់លោក។

អ្នករិះគិតជាមួយលោក ក៏ពិតជាបានចូលរួមក្នុងប្រវត្តិសាស្ត្រដ៏យូរអង្វែង នៃព្រះសហគមន៍នាសតវត្សទី២០ ដែលមានមហាសន្និបាតវ៉ាទីកង់ទី២ និងការអនុវត្តិតាមមហាសន្និបាតនោះដែរ។

អ្នករិះគិតជាមួយលោក ក៏បានយល់ដល់ចិត្តគំនិតមនុស្សដែលប៉ុលពតបានភ្ជាប់លើឈើឆ្កាង ជាមនុស្សដែលឈ្នះសេចក្ដីស្លាប់ ដ្បិតតាំងពីព្រះយេស៊ូចូលក្នុងប្រវត្តិសាស្ត្រមនុស្សយើង ជីវិតឈ្នះសេចក្ដីស្លាប់ជានិច្ច។

អ្នកអង្គុយជាមួយលោក ក៏ស្ងប់ស្ងៀមក្នុងចិត្តនិងរំភើបចិត្តជាខ្លាំង ដើម្បីបន្តប្រកាសដំណឹងល្អដូចលោកបានប្រកាសដោយមិនឈប់ឈរ ដោយយកចិត្តទុកដាក់ជាខ្លាំង និងដោយចិត្តសុភាពរាបសា។

អ្នកស្ដាប់លោក ក៏បណ្ដោយខ្លួនឲ្យភ្ញាក់ឡើងដោយការវិភាគដ៏ភ្លឺថ្លារបស់លោក និងដោយសេចក្ដីអធិប្បាយយ៉ាងត្រឹមត្រូវដាស់តឿនគេឲ្យភ្ញាក់ស្មារតី។

វត្តមានរបស់លោកពិតជាជួយគាំទ្រខ្ញុំយ៉ាងខ្លាំងផុត នៅពេលដែលខ្ញុំចាប់ផ្ដើមបំពេញមុខងារជាអភិបាល។ ខ្ញុំមានមោទនភាពដែលបានបន្តមុខតំណែងរបស់លោក។ ខ្ញុំសូមផ្ញើខ្លួនខ្ញុំឲ្យលោកអង្វរព្រះជាម្ចាស់ឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំអាចបន្តណែនាំប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ឆ្ពោះទៅកាន់ព្រះយេស៊ូជាពន្លឺបំភ្លឺប្រជាជាតិនានា។

ខ្ញុំសូមអរគុណលោកដោយស្មោះអស់ពីដួងចិត្ត!
សូមព្រះនាងម៉ារីជាមាតាព្រះសហគមន៍ជួយការពារនិងថែរក្សាលោក
សូមលោកមានអាយុយឺនយូរ។

អូលីវីយេ ផ្មិតហាស្មៀរ

# ប្រកួតកីឡាដើម្បី មិត្តភាព

ព្រះវិហារសន្តីម៉ារីញញឹម (ចំការទៀង) បានរៀបចំកម្មវិធីប្រកួតកីឡាមិត្តភាពដើម្បីអបអរសាទរក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ដែលមានអ្នកចូលរួមប្រមាណ៥០០នាក់ មកពីព្រះសហគមន៍នានាក្នុងភូមិភាគភ្នំពេញ ប្រព្រឹត្តទៅនៅថ្ងៃទី០៨ មេសា នៅវិទ្យាល័យសន្តហ្វ្រង់ស្វ័រ ស្ថិតក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។

លោកអូលីវីយេ ឝ្មីតអីស្ល៊េរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានប្រសាសន៍ថា ការប្រកួតកីឡានេះមានគោលបំណងតែមួយ គឺកសាងមិត្តភាព សាមគ្គីភាព និងធ្វើឲ្យទំនាក់ទំនងកាន់តែមានភាពជិតស្និទ្ធរវាងគ្នានិងគ្នា និងដើម្បីចូលរួមសប្បាយក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ហើយក៏ជាសក្ខីភាពបញ្ជាក់ថាយើងទាំងអស់គ្នាពិតជាបងប្អូនក្នុងមហាគ្រួសារព្រះយេស៊ូពិតមែន ។

ការប្រកួតកីឡាមិត្តភាពនេះ មានការចូលរួមពីក្រុមកីឡាករកីឡាការិនីមកពីបណ្ដាមណ្ឌលសកម្មភាពព្រះសហគមន៍ និងស្ថាបនព្រះសហគមន៍ដូចជា៖ "តាកែវ កំពត ខេត្តព្រះសីហនុ ខេត្តកែប រាជធានីភ្នំពេញ អង្គការម៉ារីណុល និងអង្គការភាពញញឹមនៃកុមារ"។

យុវជន ហ៊ុត និមល ជាកីឡាករបាល់ទាត់ និង បាល់ទះនៃវិទ្យាស្ថានសន្តប៉ូល បានឲ្យដឹងថា ៖ "កម្មវិធីនេះ បានធ្វើឲ្យយើងទទួលបាននូវពិសោធន៍ថ្មីមួយ គឺស្គាល់តម្លៃនៃមិត្តភាព និងជាឱកាសឲ្យយុវជន មកពីគ្រប់ទីកន្លែងស្គាល់គ្នាទៅវិញទៅមក និងចែកចាយនូវអំណរសប្បាយជាមួយគ្នា"។

ក្នុងការប្រកួតនេះ មានវិញ្ញាសាដូចជា៖ វិញ្ញាសាបាល់ទាត់បុរស-នារី បោះប៊ូលបុរស-នារី បាល់បោះនារី។ ឆាក លាំង

## Friendship Match

Saint Mary of smile Church in Takeo province organized a friendship match welcoming Khmer New Year, attended by about 500 people from Phnom Penh Apostolic Vicariate, held on April 8 in St. Francior High School in Kus Commune, Tram Kork District, Takeo province.

Apostolic Vicar of Phnom Penh, Bishop Olivier said that the sporting contest is to build friendship, solidarity and make relationships more closely with each other and to rejoice at a Khmer New Year occasion. It is a testimony that we are all brothers and sisters in a real family of Jesus.

The match was attended by Football men and women from Pastoral Centers and Church institutions: Takeo, Kampot, Sihanoukville, Kep, Phnom Penh, Maryknoll NGO.

Hout Nimol,a soccer and volleyball players of Saint Paul Institute said: “ this event helped us to have new experience such as values of friendship and getting to know each other and share the joy together. “






# ព្រះសហគមន៍សន្តយ៉ូសែប រៀបចំថ្វាយអភិបូជា រំឭកសន្តយ៉ូសែប ជាឧបការីនៃព្រះសហគមន៍របស់ខ្លួន



ព្រះសហគមន៍សន្តយ៉ូសែប(ផ្សារតូច)ភ្នំពេញបានរៀបចំធ្វើពិធីថ្វាយអភិបូជាយ៉ាងឱឡារិក ដើម្បីរំឭកដល់សន្តយ៉ូសែប ជាឧបការីនៃព្រះវិហារនេះ កាលពីរសៀលថ្ងៃទី១៩ ខែមីនា កន្លងទៅ ដោយមានលោកអភិបាល និងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករចូលរួម។

លោកប៊្រុយណូ កូសម៍ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍សន្តយ៉ូសែបនេះមានប្រសាសន៍ថា៖ កម្មវិធីនៅថ្ងៃនេះ យើងសូមអរព្រះគុណព្រះជាម្ចាស់ចំពោះព្រឹត្តិការណ៍ដ៏សំខាន់ៗ ដែលបានកើតឡើងរួមមាន៖ ទី១ រំឭកសន្តយ៉ូសែបដែលឧបការីនៃព្រះ សហគមន៍សន្តយ៉ូសែប(ផ្សារតូច)។ទី២ថ្វាយអភិបូជាអរព្រះ គុណព្រះជាម្ចាស់សម្រាប់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ។ ទី៣គឺអបអរគម្រប់ខួប៣ឆ្នាំនៃការតែងតាំងជាអភិបាលរបស់លោកអូលីវីយេ ឆ្មីតអ៊ីស្លែរ។ និងទី៤គម្រប់ខួប៥៦ឆ្នាំដែលលោកអភិបាល អ៊ីវរ៉ាមូសបានមកដល់ប្រទេសកម្ពុជាលើកដំបូង។

លោកអភិបាលអូលីវីយេ បានរំលឹកដល់គ្រីស្តបរិស័ទឲ្យយកសន្ុតយ៉ូសបែជាគំរូទាំងជំនឿនិងរបៀបរស់នៅជាគ្រួសារ។ លោកសង្កត់ធ្ងន់ថា៖ យើងអធិដ្ឋានដោយជំនឿដើម្បីឲ្យយើងនឹកឃើញអំពីព្រះអំណោយទាន ដែលព្រះជាម្ចាស់ប្រោសប្រទានមកយើង។ ជំនឿរបស់យើងបានណែនាំឲ្យយើងខិតខំបម្រើអ្នកដទៃ និងឲ្យយើងខិតខំរស់នៅតាមព្រះយេស៊ូ។ លោកយ៉ូសែបបានបង្កើតក្រុមគ្រួសារដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ដែលជាគំរូសម្រាប់ក្រុមគ្រួសារទាំងអស់ ហើយក្រុមគ្រួសារទាំងនេះជាសញ្ញានៃព្រះសហគមន៍៕

## St. Joseph Church Holds Mass Remembering Saint Joseph As HerPatron

St Joseph Church (PsarToich) held Mass reminding Saint Joseph, a patron of this church on March 19th presided by bishop Olivier, attended by many Christians.

Bruno Cosme, a priests in charge of the St. Joseph Church said that today's programme, We express our thanks to God main events happened:Fist, that reminded saint Joseph, a patron of this Church, second celebrate Mass thanking God for a new Pope Francisco, third,mark 3-year ordination anniversary of Mgr. Olivier as Bishop of Phnom Penh Apostolic Vicariate. And fourth, mark 56-year anniversary of Mgr. Yves Ramousse arrived in Cambodia first.

Bishop Olivier reminded Catholics to follow St. Joseph's example both faith and a lifestyle in families. He stressed: " We pray with faith to remember a gift from the God given to us. Our faith guided us to serve others and to try hard to live with Jesus' life. Saint Joseph formed holy families of God that are models for all the families. These families are signs of the Church."

# ពិធីដង្ហែររូបសំណាកសន្តយ៉ូសែបនៅព្រះសហគមន៍សន្តយ៉ូសែប



ព្រះសហគមន៍សន្តយ៉ូសែប(សែនសុខ) បានរៀបចំកម្មវិធីរំលឹកដល់ឧបការី នៃព្រះសហគមន៍របស់ខ្លួន ស្ថិតភូមិសែនសុខទី១ សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមីនា ដោយមានរៀបចំដង្ហែររូបសំណាកសន្តយ៉ូសែបចូលក្នុងព្រះវិហារ និងថ្វាយអភិបូជាក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ព្រមទាំងបងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

លោកវ៉ាំងសង់ សេន័យឆាល់ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍សន្ត យ៉ូសែបនេះមានប្រសាសន៍ថា៖ នៅថ្ងៃនេះយើងធ្វើបុណ្យរំឭក សន្តយ៉ូសែប គឺយើងចង់ឲ្យបងប្អូនបានសប្បាយរួមជាមួយគ្នា និងរំលឹកអំពីគំរូដ៏ល្អសម្រាប់ក្រុមគ្រួសារលោកយ៉ូសែប និងព្រះនាងម៉ារី ជាមនុស្សសុចរិត ចិញ្ចឹម ថែរក្សា និងអប់រំព្រះកុមារយេស៊ូ។

លោកអភិបាលអូលីវីយេបានលើកទឹកចិត្តគ្រីស្តបរិស័ទនៅទីនេះ ដោយឲ្យពួកគាត់មានជំនឿនិងមានសេចក្តីសង្ឃឹមយ៉ាងមាំលើព្រះយេស៊ូ ដើម្បី រួមដំណើរជាមួយព្រះអង្គ។

លោកនិយាយថា "នៅថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ចំពោះជីវិត ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង។ ជីវិតថ្មី គឺជាជីវិតដែលពេញលក្ខណៈនៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក។យើងសូមអង្វរព្រះជាម្ចាស់សូមឲ្យយើងរួមដំណើរជាមួយព្រះយេស៊ូដោយអរព្រះគុណព្រះជាម្ចាស់ ដោយសារព្រះអង្គផ្តល់ជីវិត គឺជីវិតដ៏បរិបូរណ៌ ហើយយើងបន្តដំណើររួមជាមួយព្រះយេស៊ូ ដោយបន្តសេចក្តីសង្ឃឹមក្នុងជីវិតរបស់យើង"។

លោកបូជាចារ្យវ៉ាំសង់បន្ថែមថាគណកម្មការព្រះសហគមន៍នៅទីនេះបានបង្កើតថ្នាក់អប់រំអក្ខរកម្មភាសាខ្មែរ និងថ្នាក់ហាត់របាំដល់កុមារតូចៗ ព្រោះពួកគាត់ភាគច្រើនជាជនជាតិវៀតណាម ហើយយើងក៏មានក្រុមកាយរិទ្ធផងដែរ។

គួរបញ្ជាក់ផងដែរថា៖ព្រះសហគមន៍សន្តយ៉ូសែប(សហគមន៍សែនសុខ) នេះគឺជាអតីតព្រះសហគមន៍នៅតំបន់ប៊ូឌិញ ដែលបានធ្វើការផ្លាស់ប្តូរមករស់នៅក្នុងសង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវនេះកាលពីឆ្នាំ២០០១ កន្លងមក ៕

## Anlong Kgan Church Celebrates Its Patron Saint Day

Saint Joseph is the patron saint of Anlong Kgan church l located in Sen Sok 1 village, khmuonh district, Sen Sok commune , Phnom Penh city. The feast was celebrated last March 17th and presided by Bishop Olivier.

Fr. Vincent Senechal, the priest in charge of this community, said: today we honored Saint Joseph who is our church patron saint. We organized this event in order to give time for parishoners to celebrate together and remind of Saint Joseph and the Blessed Virgin Mary who looked after the education of child Jesus. It is a good example for the families.

Bishop Olivier encouraged Catholics to keep growing in faith and to journey with Jesus in their own lives.

He said that “today we thank God for our lives that God gave us. Our new life has started since we were baptized. We pray God to help us in our daily life with Jesus by giving thanks to him who grants us everlasting life and hope."

Father Vincent added that in Anlong Kgan church were created literacy class and Khmer traditional dance courses for children. We also have a scout group too.

St. Joseph Church is a former community of Building in Phnom Penh which was moved to Sen Sok since 2001.

# បុណ្យចម្លងជាពិធីដ៏សំខាន់មួយក្នុងប្រពៃណីនៃគ្រីស្តសាសនា



ព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង ស្ថិតក្នុងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បានប្រារព្ធពិធីបុណ្យចម្លងនាថ្ងៃទី៣១ ខែមីនា ដែលមានការចូលរួមជាអធិបតីពីលោកអូលីវីយេ ដ្មឹតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងគ្រីស្តបរិស័ទមកពីព្រះសហគមន៍នានាប្រមាណ៣០០នាក់។

លោកអាន ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍នេះ បានឲ្យដឹងថា ៖ ពិធីបុណ្យចម្លងធ្វើឡើងជារៀងរាល់ឆ្នាំដើម្បីរំលឹកពេលដែលព្រះជាម្ចាស់បានរំដោះជនជាតិអ៊ីស្រាអែលពីអេហ្ស៊ីប។ ម្យ៉ាងទៀតបុណ្យនេះក៏រំលឹកពីការសោយទីវង្គត និងមានព្រះជន្មរស់ឡើងវិញដ៏រុងរឿងរបស់ព្រះយេស៊ូ។

ក្នុងឱកាសនោះ ព្រះសហគមន៍សន្តីម៉ារីញញឹម (ចំការទៀង) មានយុវជន ទទួលអគ្គសញ្ញាជ្រមុជទឹកនាថ្ងៃបុណ្យចម្លងនេះមានចំនួន៣៤នាក់ ។ លោកបូជាចារ្យអាន បន្តថា៖ "ពីដើមរៀងមកព្រះសហគមន៍ បានធ្វើអគ្គសញ្ញាជ្រមុជទឹកនៅថ្ងៃបុណ្យចម្លងដល់យុវជន មានន័យថា គឺឲ្យពួកគាត់រួមជីវិតថ្មី ជាមួយព្រះយេស៊ូដោយរួមស្លាប់រួមរស់ជាមួយព្រះអង្គ"។

លោកអភិបាលមានប្រសាសន៍ថា៖ យើងត្រូវជួប និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូពេញមួយជីវិត និងកសាងព្រះរាជ្យព្រះជាម្ចាស់ក្នុងសង្គមយើង ដោយប្រានចោលទាំងស្រុងនូវភាពអយុត្តិធម៌ និងការរើសអើង ចៀសវាងស៊ាំទៅនឹងភាពអយុត្តិធម៌នៅក្នុងសង្គមដែលយើងកំពុងរស់នៅ។ ហើយម្នាក់ៗត្រូវមានកម្លាំងចិត្តក្នុងការប្រកាសដំណឹងល្អ រស់ក្នុងក្រុមគ្រួសារតែ១ និងហ៊ានធ្វើជាសាក្សីនៃអំណរសប្បាយដែលមកពីព្រះជាម្ចាស់។ យុវជនចន បូរី អ្នកទទួលអគ្គសញ្ញាជ្រមុជទឹកបានឲ្យដឹងថា៖ "ខ្ញុំចង់ប្រកាសដំណឹងល្អតាមរយៈធ្វើជាគ្រូអប់រំជំនឿ និងជួយអ្នកក្រីក្រ"។

កញ្ញាឆាយ ពិសី បានឲ្យដឹងដែរថា៖ "ខ្ញុំហាក់បីដូចជាបានទទួលពន្លឺពីព្រះជាម្ចាស់ និងចង់ដើរតាមព្រះយេស៊ូ ហើយលះបង់អំពើបាបទាំងពួង"។

យុន សំអាត

## Easter Is An Important Event In The Catholic

Saint Mary of smile Church at Chamkar Tieng Village, Kous Commune, Tram Kak District, Takeo Province, celebrated Easter on March 31, presided by Bishop Olivier with about 300 Christians.

Father Anne, a priest in charge of this church said:"we celebrate Easter every year to remind of the liberation of Israeli from Egypt by God. On the other hand, this feast has also reminded the death and resurrection of Jesus Christ."

On the occasion, The Saint Mary of smiled Church (Chamkar Tieng) there were 34 baptized at Easter. Father Anne continued that from the beginning, the Church has baptizedyouths at Easter Day. This means that they joined anew life with Jesus."

Bishop Olivier said: "We have to meet and to have close relationship with Jesus for life and build the Kingdom of God in our society, steadfastly rejecting injustice and discrimination, avoid being accustomed to injustice in a society in which we are living. And each must have the strength to spread the Gospel, living in one family, daring to bear witness of the joy that comes from God.

A youth, Jon Borey said: "I want to announce the Gospel as a catechist and to help the poor."

Miss Chhay Pisey said: "I seem to have received the light of God and want to follow Jesus as well as renounce sin."

# ពិធីដើរផ្លូវព្រះឈើឆ្កាងនៅព្រះវិហារដ៏ចំណាស់លើភ្នំបូកគោ



គ្រីស្តបរិស័ទតំបន់កំពតប្រមាណជាង២០០នាក់ បានប្រារព្ធពិធីអធិដ្ឋានផ្លូវព្រះឈើឆ្កាង នៅបរិវេណព្រះវិហារចាស់លើភ្នំបូកគោ នាថ្ងៃទី២៩ មីនា ដឹកនាំដោយលោកហ្វេណាន់ដូ ជំនួយបូជាចារ្យនៅព្រះសហគមន៍កាតូលិកកំពត។

លោកបូជាចារ្យបានមានប្រសាសន៍ថា៖ យើងប្រារព្ធពិធីដើរផ្លូវឈើឆ្កាងនេះឡើង ដើម្បីជួយឲ្យគ្រីស្តបរិស័ទទាំងអស់រិះគិតពីក្តីឈឺចាប់វេទនា ឬពេលដែលមានបញ្ហា គេត្រូវតែអធិដ្ឋានទៅព្រះយេស៊ូដែលបានរងទុក្ខលំបាកមុនយើង និងដើម្បីរួមដំណើរជាមួយព្រះអង្គ និងអង្វរទ្រង់ជួយរំដោះបាប។ ម្យ៉ាងទៀត គឺពិធីនេះ ជួយឲ្យគេយល់ថារាល់ឧបសគ្គនិងរាល់ទុក្ខលំបាកទាំងឡាយមិនមែនជាហេតុផលដែលនាំឲ្យយើងបរាជ័យនោះឡើយ"។

លោកគ័ង ទឹង មកពីព្រះសហគមន៍ព្រែកប្រស់ និយាយថា ៖ "អ្វីដែលខ្ញុំចាប់អារម្មណ៍ជាងគេ គឺដំណើរជីវិតរបស់ព្រះយេស៊ូ។ ព្រះអង្គបានទទួលទារុណកម្មយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែទ្រង់មិនបានពោលពាក្យថា លំបាកនោះទេ នោះគឺជាសេចក្តីស្រឡាញ់របស់ព្រះយេស៊ូគ្រីស្ត ព្រោះព្រះអង្គបានបូជាជីវិតដើម្បីសង្គ្រោះប្រជាជាតិទាំងមូល"។

កញ្ញានាក់ កញ្ញា មកពីព្រះសហគមន៍ជុំគីរីបានឲ្យដឹងថា៖ "ខ្ញុំកំពុងចូលរួមដំណើរលើឈើឆ្កាងរបស់ខ្ញុំឡើងទៅលើភ្នំលលាដ៏ក្បាលជាមួយព្រះយេស៊ូដែរ។ ក្នុងជីវិតជាគ្រីស្តបរិស័ទបានធ្វើឲ្យខ្ញុំដឹងពីកំហុសខ្លួនឯង និងធ្វើឲ្យខ្ញុំកែប្រែចិត្តគំនិតឡើងវិញហើយខ្ញុំនឹងប្រឹងជម្នះរាល់ទុក្ខលំបាកប្រចាំថ្ងៃរបស់ខ្ញុំ"។

នេះជាលើកទីមួយហើយដែលព្រះសហគមន៍កាតូលិកបានទទួលការអនុញ្ញាតពីក្រុមហ៊ុនដែលទទួលសិទ្ធិអភិវឌ្ឍន៍ភ្នំបូកគោដើម្បីរៀបចំធ្វើពិធីបុណ្យតាមគ្រីស្តសាសនានៅព្រះវិហារកាតូលិកដ៏ចំណាស់នេះ ដែលកសាងឡើងក្នុងសម័យអាណានិគមបារាំង ដើម្បីរៀបចំសម្រាប់ការជួបជុំគ្នាអធិដ្ឋាន ថ្វាយអភិបូជា និងប្រារព្ធពិធីបុណ្យផ្សេងៗទៅតាមជំនឿព្រះសហគមន៍កាតូលិក។

## Way of Cross in the ancient temple at the Bokor Moutain

More than 200 Christians from a Kampot region walked the way of Cross in the old Church at the Bokor Moutain on March 29, led by Father Fernando Arango, a priests assistant of Kampot pastoral center.

The priest said: “ We walk the way of Cross in order to help all Catholics to reflect on their own suffering or in a troubled time, they must pray to Jesus who suffered before them; and to travel with Him and ask Him to forgive our sin. On the other hand, this ceremony helps Catholics to understand that all the obstacles and suffering that were not the reason leading us to fail.”

Mr. Korng Ting, from Prek Pros Church said: “What I am interested most is the life of Jesus. He was punished severely. But he did not make any mention of this suffering; that is the love of Jesus Christ because he laid down his life for the salvation of the whole nation. “

Kagna from Chum Kiri Church said: “ I am joining my cross with Jesus to the Calvary Mountain. In a Christian life prompted me perceive my mistakes and need to reform myself as well as struggle to overcome all of my daily suffering.”

This is the first time that the Catholic communities have been granted permission from companies who are entitled to develop the Bokor Mountain in order to hold the oldest Catholic ceremonies, which was built during the French colonial era to hold prayer gathering, Mass, ceremonies in accordance with the Catholic faith.






# ពិធីប្រោះទឹកព្រះពរមណ្ឌលថែទាំអ្នកជម្ងឺ ព្រះសហគមន៍

គណកម្មាការមណ្ឌលសុខភាពនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានរៀបចំពិធីប្រោះទឹកព្រះពរដល់ទីតាំងថ្មីនៃមណ្ឌលថែទាំអ្នកជម្ងឺព្រះសហគមន៍កាតូលិកសន្តលូកា ដែលស្ថិតនៅផ្ទះលេខ១៣ ផ្លូវលេខ៥៣៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញកាលពីថ្ងៃទី២៣ ខែមេសា កន្លងទៅ ក្រោមអធិបតីភាពរបស់លោកអភិបាលអូលីវីយេ ដ្មឹតអឺស្លែរ។

លោកអភិបាលបានមានប្រសាសន៍ថា ៖ មណ្ឌលថែទាំអ្នកជម្ងឺនេះ បន្តសកម្មភាពពីព្រះសហគមន៍សន្តយ៉ូសែប( ផ្សារតូច )។ ហើយឈ្មោះរបស់មណ្ឌលនេះ គឺជាឈ្មោះរបស់សន្តលូកាជាអ្នកនិពន្ធគម្ពីរដំណឹងល្អ និងជាគ្រូពេទ្យម្នាក់។ លោកបន្តថា ៖នៅទីនេះបានបង្កលក្ខណៈងាយស្រួលដល់យើងក្នុងការស្វាគមន៍យ៉ាងរាក់ទាក់ និងផ្តល់ភាពកក់ក្តៅ ដល់អ្នកជម្ងឺដែលបានមកសម្រាកព្យាបាលពីតាមខេត្តនានា។ កិច្ចការនេះយើងធ្វើក្នុងនាមព្រះយេស៊ូ ដោយបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកជម្ងឺ ដូចព្រះជាម្ចាស់ បានបង្ហាញសេចក្តីស្រឡាញ់ដល់យើងដែរ។

កញ្ញា មីឡេណា ប៉ែតទី ប៉ុតទ្រីស ជាអ្នកទទួលខុសត្រូវគណៈកម្មការមណ្ឌលសុខភាពបានមានប្រសាសន៍ឲ្យដឹងថា៖ "នៅក្នុងមណ្ឌលថែទាំអ្នកជម្ងឺព្រះសហគមន៍សន្តលូកា គឺជាមណ្ឌលស្នាក់នៅបណ្តោះអាសន្នសម្រាប់អ្នកជម្ងឺមកពីបណ្តាខេត្តផ្សេងៗ ដែលស្វែងរកការព្យាបាលជម្ងឺនៅរាជធានីភ្នំពេញ។ យើងផ្តល់កន្លែងស្នាក់នៅ ផ្តល់អាហារ ជួយពិនិត្យជម្ងឺ ជួយបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យ និងការអប់រំអនាម័យសុខភាពដល់ពួកគាត់ផងដែរ។

លោកហេង ហួត ជាវេជ្ជបណ្ឌិតប្រចាំការនៅមណ្ឌលថែទាំអ្នកជម្ងឺសន្តលូកាបានថ្លែងអំណរគុណចំពោះលោកអភិបាលអូលីវីយេដែលបានខិតខំយកអស់កម្លាំងកាយចិត្តនឹងគាំទ្រជាថវិការចំពោះមណ្ឌលនេះ។ លោកបានមានប្រសាសន៍សង្កត់ធ្ងន់ថា៖ មណ្ឌលនេះជួយយើងឲ្យមានទំនាក់ទំនងកាន់តែល្អក្នុងសង្គមដែលប្រកបដោយសីលធម៌ កិច្ចការមនុស្សធម៌ និងការទទួលខុសត្រូវ ។







# ការគូលិកសន្តលូកា

## Blessing of St Luke Sick Shelter

Last April 23rd, Bishop Olivier Schmitthaeusler, Apostolic Vicar of Phnom Penh, blessed the new house of St Luke Sick Shelter, located No. 13, Street 538, Boeung Kak I, Phnom Penh.

St Luke Sick Shelter is runned by the Health Pastoral Committee of Phnom Penh Vicariate.

Bishop said: This center continues the work from St. Joseph Church (Phsar Tauch). The name of the center is “St. Luke”, who is the author of one gospel and was a physician. He said: This place is a good one to welcome friendly and give comfortable place to patients from the provinces. This work is to be done in the name of Jesus by showing our love to them as God loves us.

Ms. Betty Beatriz Millena, the person in charge of Health Pastoral Communittee told that this center is a temporary accommodation shelter for patients from the provinces who come for treatment in Phnom Penh. Here, we provide accommodation, food, and medical assistance, and we refer patients to the government hospitals and educate them about hygiene.

Mr. Heng Huot, doctor at St Luke center gave thanks to Bishop Olivier for his financial support for the center. He stressed that this center helps us to have better communicate in society, to have ethical practice in humanitarian affairs.

# រូបភាពក្នុងរដូវបុណ្យចម្លង និងចូលឆ្នាំប្រពៃណីជាតិ

















# យុវជនចូលរួមសកម្មភាពក្នុងសង្គម

ជារៀងរាល់ថ្ងៃអាទិត្យ យុវជនយុវនារីនៅព្រះសហគមន៍កាតូលិកត្រែងត្រយឹង បានជួបជុំគ្នាដើម្បីធ្វើសកម្មភាពរួមគ្នា ដូចជា ចុះសួរសុខទុក្ខអ្នកក្រីក្រតាមភូមិ ធ្វើកិច្ចការមួយចំនួនក្នុងព្រះសហគមន៍ និងរិះគិតពីគម្រោងការផ្សេងៗទៀត។

លោកលេង ហុងជាគណកម្មាព្រះសហគមន៍ត្រែងត្រយឹង បានឲ្យដឹងថា យុវជនយុវនារីទាំងនោះភាគច្រើនជាកូនរបស់គ្រីស្តបរិស័ទ និងមួយចំនួនទៀតជាកូនរបស់ពុទ្ធបរិស័ទដែលមករៀនក្នុងព្រះសហគមន៍មានចំនួនប្រមាណជាង១០នាក់។ ហើយកិច្ចការដែលពួកគេធ្វើនៅក្នុងព្រះវិហារនោះមានដូចជា ចាំងស្មៅ និងកាត់មែកឈើ សំអាតបរិវេណព្រះវិហារ បោសជូតថ្នាក់រៀននិងព្រះវិហារ និងរៀបចំកន្លែងអធិដ្ឋាន។

លោកបានបន្តថា ក្រៅពីនោះ ប្រសិនបើពួកគេទំនេរ ពួកគេចុះតាមភូមិជិតៗដើម្បីសួរសុខទុក្ខអ្នកភូមិ ជាពិសេសអ្នកក្រីក្រ ដោយលើកទឹកចិត្ត និងផ្តល់សំភារៈខ្លះៗដល់ពួកគាត់។ លោកបានបញ្ជាក់ថា រាល់សប្តាហ៍យុវជនទាំងអស់នោះបានប្រមូលប្រាក់ដាក់រួមគ្នាក្នុងម្នាក់១០០០រៀល។ ការសន្សំប្រាក់នេះ គឺដើម្បីជួយទិញនំដល់ក្រុមកុមារកាយរិទ្ធ សម្រាប់ដំណើរកំសាន្តជាក្រុម ទិញឧបករណ៍សំរាប់ប្រើប្រាស់ និងទិញអង្ករជួយដល់ជនក្រីក្រ និងអ្នកជំងឺអេដស៍នៅភូមិឆ្ងាយៗ។

យុវនារី អៀង ស្រីឡាង មានអាយុ ១៦ឆ្នាំ ជាពុទ្ធបរិស័ទ បានមករៀននៅទីនេះហើយចូលរួមក្រុមយុវជនបានឲ្យដឹងថា "ខ្ញុំមានអារម្មណ៍សប្បាយចិត្តណាស់ ដោយសារមិត្តភ័ក្តខ្ញុំចេះស្រលាញ់គ្នា និងចេះជួយគ្នាទៅវិញទៅមក ដោយមិនចេះរើសអើងគ្នាទេ ខុសប្លែកពីមិត្តភ័ក្តដែលនៅខាងក្រៅ"។ ស្រីឡាងបានបន្តថា ពិសេសទៅទៀតនោះ គឺនៅពេល លោកគ្រូនាំពួកយើងទៅតាមភូមិ ស្វែងរកបងប្អូនក្រីក្រ និងជួយគេតាមលទ្ធភាពដែលយើងមាន។ ស្រីឡាង បញ្ជាក់ថា "ខ្ញុំដូចជាមានមោទនភាពណាស់ ព្រោះខ្ញុំមិនដែលនឹកស្មានថាខ្លួនរបស់ខ្ញុំអាចចូលរួមចំណែកជួយដល់សង្គមទេ!"



## Youth Participates in Social Activities

Every Sunday, young people in Traeng Trayueng parish gather together to visit the poor of the village, do some work in the church and set plans for their own group.

Leng Hong, head of the parish committee, said that most of them are Catholics and some are Buddhist. More than 10 people come to the church to study English and catechism. So every Sunday, they have some activities such as cleaning the classrooms and the church, prepare material for prayer, and visit the poor.

He told that every week, all young people collect 1000 riels to help scouts activity with children, buy equipment for their activity, and buy rice to help the poor and AIDS families in the village.

Ieng Sreylang, 16 year-old, a Buddhist, said she comes here to learn English. She added: "I feel very happy because of the friends whom I know who love and help each other. They are different of my other friends. Specially, the teacher leads us in the village to visit the poor.

She continued that she feels very proud of this group because she never imagined that she could contribute to the good of the society!"

# លោកអូលីវីយេ ឝ្មីតអីស្លែរ ដាស់តឿនយុវជន-នារី ឲ្យគិតអំពីនិងឆ្លើយ ៖

ពិធីថ្វាយពាក្យសច្ចាប្រណិធាននិរន្តររបស់បងស្រី ស្រី សុជាតិ នៅព្រះសហគមន៍កំពង់ចាមក្រុង នាថ្ងៃទី២០ មេសាកន្លងទៅនេះ លោកអភិបាលអូលីវីយេ ឝ្មីតអីស្លែរ បានជំរុញឲ្យយុវជន-នារីរិះគិតនិងឆ្លើយតបចំពោះការត្រាស់ហៅទៅជាអ្នកបួស។

លោកអភិបាលបានមានប្រសាសន៍ថា "មនុស្សយើងសព្វថ្ងៃ មានអ្វីៗគ្រប់គ្រាន់តាមរបៀបរស់នៅក្នុងសង្គម ប៉ុន្តែអ្វីៗទាំងនោះមិនអាចចិញ្ចឹមយើងបានទាំងអស់ទេ គឺមានតែព្រះយេស៊ូដែលបានផ្តល់ឲ្យជីវិតរបស់យើងទទួលបាននូវលក្ខណៈពេញលេញ"។

ហេតុនេះ លោកអភិបាលបានជំរុញ និងលើកទឹកចិត្តបន្ថែមទៀតដល់យុវជន ដើម្បីឲ្យពួកគាត់មើលឃើញអំពីអនាគតរបស់ព្រះសហគមន៍កម្ពុជា ដើម្បីឲ្យព្រះសហគមន៍នេះក្លាយជាព្រះសហគមន៍ខ្មែរពិតៗ ដោយមានបងប្រុស បងស្រី អ្នកបួសជាជនជាតិខ្មែរ។

លោកអភិបាលបន្តទៀតថា យើងជាអភិបាល យើងបម្រើព្រះសហគមន៍នេះ។ តែយើងក៏ត្រូវការបងប្អូនខ្មែរដែលសុខចិត្តថ្វាយខ្លួន ដើម្បីឲ្យព្រះសហគមន៍នេះទៅមុខបន្តទៀត។ យើងក៏មានក្រុមរិះគិតអំពីការត្រាស់ហៅមួយចំនួន ដូចជាក្រុមសាមូអែល ក្រុមអេម៉ាណូអែល ជាដើម ដើម្បីជួយឲ្យយើងភ្ញាក់ស្មារតីថាយើងជាព្រះសហគមន៍ "ខ្ញុំបម្រើព្រះសហគមន៍របស់ខ្ញុំដើម្បីឲ្យព្រះសហគមន៍ខ្ញុំមានអនាគត និងឲ្យខ្ញុំធ្វើសាក្សីនៃព្រះយេស៊ូ"។

លោកក៏បានលើកទឹកចិត្តដល់យុវជន-នារី កុំឲ្យគិតថាខ្លួននៅក្មេងពេក ហើយគ្មានសមត្ថភាពបម្រើព្រះសហគមន៍ ដោយសារគ្មានចំណេះដឹង និងខ្លាចឪពុកម្តាយមិនអនុញ្ញាត។ លោកអភិបាលអូលីវីយេ បានលើកឧទាហរណ៍របស់ព្យាការីសាមូអែលដែលព្រះជាម្ចាស់បានត្រាស់ហៅកាលគាត់នៅជាកុមារនៅឡើយ។ ព្រះជាម្ចាស់មានបន្ទូលមកគាត់ថា "កុំខ្លាចអី ខ្ញុំគង់នៅជាមួយ និងខ្ញុំធ្វើដំណើរជាមួយ"។ លោកអភិបាលបានបន្តថាការត្រាស់ហៅមិនត្រូវគិតយូរ រហូតដល់រាប់ឆ្នាំនោះឡើយ។

នៅចុងបញ្ចប់ លោកបាននិយាយថា "ខ្ញុំសង្ឃឹមថា នៅថ្ងៃនេះ អ្វីដែលបងប្អូនបានឃើញនឹងជំរុញឲ្យមានសេចក្តីរំភើប និងត្រេកអរ ណែនាំឲ្យប្អូនចង់ធ្វើតាមដែរ ដោយសារព្រះយេស៊ូត្រាស់ហៅយើង"។

នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃមានសាសនាទូត និងបព្វជិត





# ះ តបចំពោះការត្រាស់ហៅ

បព្វជិតា ប្រមាណជាង៣០០នាក់ និងមានបូជាចារ្យជនជាតិខ្មែរចំនួន៥អង្គ និងបងស្រីជនជាតិខ្មែរចំនួន១០នាក់ប៉ុណ្ណោះ ដែលកំពុងបម្រើការនៅក្នុងប្រទេសកម្ពុជានៅតាមព្រះសហគមន៍ទាំងបីភូមិភាគ។

## Bishop Olivier Schmitthaeusler urges young people to think about vocation

In his homily for the final vows of Sr. Srey Socheat in Kampong Cham, last April 20th, Bishop Olivier Schmitthaeusler urged the young Catholics think about their vocation.

Bishop said that “people today have everything in their life but those things cannot fulfill all their desires, only Jesus can give a full meaning to our lives.”

Therefore, he urged and encouraged more young people to consider the future of the church in Cambodia and help her to become a real Khmer community which has Khmer brothers and sisters.

Bishop continued that as bishop, he serves this church. But we also need Khmer people who become consecrated persons and give their lives for the Church. There are groups to reflect about vocation such as Emmanuel and Samuel to help the youth realize that they are the Church and could say “I serve my community to make it alive in the next future. I want to be a witness of Jesus.”

He also encouraged youth do not be afraid of their young age or low education or family opposition to become a priest or a religious. He gave the example of the Prophet Samuel who was called by God when he was in the young age. God said to him, “Do not be afraid, I will be with you.” Bishop underlined the fact that God is calling always new young people since many centuries.

At the end, he said “I hope the vows of Sr. Socheat today will encourage you and give you the desire to follow the instructions and the call of Jesus.

In Cambodia today, we have many missionaries and religious groups which are from foreigners. More than 300 foreign missionaries serve the Church here. Only 5 Khmer priests and 10 Sisters are Cambodian.



# បឹងទំពុន ៖ ១៧នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក



មនុស្សពេញវ័យចំនួន១៧នាក់បានទទួលអគ្គសញ្ញាជ្រមុជទឹកនៅព្រះវិហារព្រះកុមារយេស៊ូ(បឹងទំពុន) ក្នុងឱកាសបុណ្យចម្លងកន្លងទៅ។ ពិធីនេះបានប្រព្រឹត្តទៅដោយមានលោក អូលីវីយេ ឆ្មីតអ៊ីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញជាអធិបតីភាព។

លោកអភិបាល បានមានប្រសាសន៍ថា យើងត្រូវនៅជាប់ជាមួយព្រះយេស៊ូ ព្រោះព្រះអង្គនៅរស់ក្នុងខ្លួនយើងម្នាក់ៗនូវរាល់ទុក្ខលំបាកនិងភាពអស់សង្ឃឹមដែលយើងមានសព្វថ្ងៃ។

លោកអភិបាលបន្តថា ក្នុងនាមជាគ្រីស្តបរិស័ទ យើងត្រូវមានចិត្តដើម្បីប្រកាសដំណឹងល្អដែលចេញពីខ្លួនរបស់យើង និងពីចិត្តរបស់យើងពិតប្រាកដមែន ដើម្បីឲ្យឈ្មោះរបស់ព្រះយេស៊ូដែលណែនាំឲ្យមនុស្សទាំងអស់មានអំណរសប្បាយពិតមែននៅគ្រប់ទីកន្លែង។ លោកបានសង្កត់ធ្ងន់ថា "ឲ្យយើងចេះយកសេចក្ដីស្រឡាញ់អស់ពីដួងចិត្ត អស់ពីជំនឿអស់ពីកំលាំងកាយកំលាំងចិត្តដើម្បីប្រកាសដំណឹងល្អ ដោយសារធម៌មេត្តាករុណារបស់ព្រះយេស៊ូគ្រីស្ត"។

លោកអភិបាលបានជំរុញឲ្យគ្រីស្តបរិស័ទទាំងអស់ ត្រូវចេះប្រមូលកំលាំងដើម្បីឲ្យព្រះរាជរបស់ព្រះជាម្ចាស់មកដល់ផែនដី គឺយើងត្រូវធ្វើយ៉ាងណាឲ្យយុត្តិធម៌និងសេចក្ដីពិត សេចក្ដីស្រឡាញ់និងសេចក្ដីសុខជួបជុំគ្នា។ លោកបានរំលឹកដែរថា យើងត្រូវជួយអ្នកក្រីក្រ និងលើសពីនេះទៀតគឺត្រូវស្រឡាញ់មនុស្សទាំងអស់ព្រោះមនុស្សទាំងអស់មានឋានៈជាបុត្រធិតារបស់ព្រះជាម្ចាស់។

ចំណុចចុងក្រោយ លោកអភិបាលបានឲ្យគ្រីស្តបរិស័ទចេះរួមគ្នាជាធ្លុងតែមួយ ដូចព្រះម្ចាស់ដែលជាធ្លុងតែមួយ ទោះបីពួកគាត់មកពីជាតិសាសន៍ផ្សេង ភាសាផ្សេងគ្នា តែត្រូវយកចិត្តទុកដាក់ដល់គ្នាទៅវិញទៅមក ដែលទាំងនេះជាមូលដ្ឋានគ្រឹះនៃការកសាងពិភពលោកថ្មី ដែលពោពេញដោយអំណរសប្បាយដ៏ពិតប្រាកដ។

## Boeng Tompoun: 17 people get baptized

17 adults received baptism at Child Jesus Church (boeng Tompoun) at the Easter Day. The event was presided by Apostolic Vicar of Phnom Penh, Bishop Olivier.

Bishop said: “ We have to united with Jesus because He lives in each of us during all trials and despair we are experiencing today.

He continued that as Christians “ We have to be sensitive to proclaiming the Good News from ourselves and our true hearts in order to let the name of Jesus guide people joyfully in every places. “ He stressed that “We have to proclaim Good News from the bottom of our heart with love and faith, strength and mind because of mercy of Christ.”

Bishop urged all the Catholics to muster all the strength for the coming of God’s Kingdom on earth. And somehow we let justice, truth, love and peace come together. He also recalled we need to help the poor and moreover we are to love all people because they are children of God.

The last point, Bishop asked Christians to live in communion with God , even though they are coming from different nations, different languages but they have to care for each other that are the foundation of building a new world full of a real joy.

# ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកែប



មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូខេត្តកែបត្រូវបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី០៧ មីនា ស្ថិតនៅភូមិថ្មីសង្កាត់ព្រៃធំក្រុងកែបខេត្តកែប ដែលមានការអញ្ជើញចូលរួមជាកិត្តិយសពីសំណាក់ឯកឧត្តមអ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា លោកអូលីវីយេ ផ្មឹតអ៊ីស្លែរ អភិបាលភូមិភាគភ្នំពេញ តំណាងមូលនិធិដុនបូស្កូកម្ពុជា និងភ្ញៀវជាតិនិងអន្តរជាតិយ៉ាងច្រើនកុះករ។

លោកឪពុកចន វីសឺរប្រធានមូលនិធិដុនបូស្កូកម្ពុជាបានមានប្រសាសន៍ថា ៖ មូលនិធិដុនបូស្កូបានបំពេញបេសកកម្មរបស់ខ្លួននៅប្រទេសកម្ពុជាចាប់តាំងឆ្នាំ១៩៩១មកម្ល៉េះ។ សព្វថ្ងៃស្ថាបនបានជួយដល់យុវជន និងកុមារក្រីក្រ ដែលពុំមានលទ្ធភាពចូលរៀននៅថ្នាក់មហាវិទ្យាល័យ។ ហើយស្ថាបនដុនបូស្កូជាដៃគូដ៏សំខាន់ ជាមួយក្រសួងអប់រំយុវជននិងកីឡា។ មជ្ឈមណ្ឌលនេះគឺជាថ្នាលផ្តល់នូវចំណេះដឹងដល់យុវជន និងកុមារក្រីក្រក្នុងប្រទេសកម្ពុជា។

លោកឪពុកលី សំណាង ជានាយកមជ្ឈ-មណ្ឌលមានប្រសាសន៍ថា ៖ ថ្ងៃនេះមូលនិធិដុនបូស្កូបានកសាងអគារសិក្សាមួយខ្នងមានពីរជាន់សម្រាប់បើកបង្រៀនផ្នែកទំនាក់ទំនងសង្គម និងសារព័ត៌មាននិងផ្នែកលេខាធិការ។ អគារនេះអាចជួយដល់យុវជននិងកុមារក្រីក្រដែលរស់នៅក្នុង ខេត្តកែប ខេត្តកំពត និងខេត្តតាកែវព្រមទាំងតំបន់ជុំវិញនេះផងដែរ។ អគារនេះប្រសិទ្ធនាមថា "អគារអង្គរបុរី"។

ក្នុងឱកាសនោះលោកអភិបាលបាន ប្រសិទ្ធពរដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកែប។ សូមព្រះជាម្ចាស់ជួយឃុំគ្រងក្នុងការបណ្តុះបណ្តាលយុវជន យុវនារីឲ្យប្រកបដោយសីលធម៌ ជំនាញ ដើម្បីអនាគតរបស់ពួកគេ។

## Inauguration of Vocational Training Center in Kep Province

Don Bosco Vocational Training Center in Kep province was officially inaugurated on March 7 in the New village, Prey Thom, Kep province by his H.E, Ministry of Education, Youth and Sport, Im Sethy and the prayer of Apostolic Vicar of Phnom Penh, Bishop Olivier , a representative of the Donbosco Foundation in Cambodia and many national and international distinguished guests.

Father John Visser, head of the Don Bosco Foundation said: the Don Bosco Foundation has carried out its mission in the country since 1991. Today, the Institution has helped youths and poor children who are not able to attend college. And the Don Bosco Institution presents a key partner with the Ministry of Education, Youth and Sports. This Center is a school nursery for knowledge of youth and poor children in Cambodia

Father Ly Samnang, a director of the Center said: Today, the Don Bosco Foundation has a building with two floors for social communications and journalism, and the Secretary courses. This program provide forpoor children and young people who live in Kep province, Kampot province, Takeo province and the surrounding area as well.

This building was named “Angkor Borei.”

On the occasion, Bishop Olivier made the blessing of the building and prays for the young people who study in the center.

Don Bosco Vocational Training CenterinKep has taught since 2002, but since then, the center had not been equipped enough so it had only sewing program for women only.

# សម្រង់សេចក្ដីអធិប្បាយព្រះបន្ទូល របស់លោកអភិបាលអូលីវីយេ ឝ្មីតអីស្លែរ ក្នុងឱកាសបុណ្យចម្លង ៣០/០៣/១៣

លក ២៤,១-១២

អបអរសាទរ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ!

អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!

៤០ថ្ងៃមុន យើងមិនបានច្រៀងអាលេលូយ៉ាទេ យើងទុកច្រៀងនៅយប់នេះ ដើម្បីបង្ហាញអំណរសប្បាយ សេចក្ដីសុខរបស់យើង ក្នុងពេលដែលយើងទទួលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ឲ្យទៅជាអាលេលូយ៉ាចេញពីបេះដូង ចេញពីចិត្តគំនិតរបស់យើង ដើម្បីបង្ហាញពីជីវិតថ្មីដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នេះជាអំណរសប្បាយរបស់យើង។

ម្សិលមិញ ខ្ញុំបានធ្វើបុណ្យព្រះយេស៊ូសោយទិវង្គតនៅព្រះសហគមន៍ចំប៉ា យើងបានដើរផ្លូវឈើឆ្កាងនៅក្នុងភូមិគ្រីស្ដបរិស័ទតាមដំណាក់ទាំង១៤។ គេបានសម្ដែងសាច់រឿងតាមដំណាក់នីមួយៗ។ នៅដំណាក់ទី១៤ គេបានរុំតួអង្គព្រះយេស៊ូនឹងក្រណាត់ស ហើយគេដាក់គាត់នៅក្នុងផ្នូរ ដែលជារោងដែលព្រះយេស៊ូប្រសូត។ ពេលនោះបានធ្វើឲ្យខ្ញុំនឹកឃើញភ្លាមដល់ព្រះយេស៊ូប្រសូត ឬព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស រហូតដល់ព្រះអង្គសោយទិវង្គត នេះគឺជាអាថ៌កំបាំងតែមួយ។ នេះជាអ្វីដែលណែនាំឲ្យមានការសង្គ្រោះ ឲ្យមានជីវិតថ្មីយាងមកនៅក្នុងពិភពលោកយើង ណែនាំឲ្យគ្រីស្ដបរិស័ទមានអំណរសប្បាយនិងរួមគ្នាដើរតាមព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។

ថ្ងៃនេះយើងមាន១៧នាក់ ដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងព្រះសហគមន៍បឹងទំពុននេះ ហើយយប់នេះនៅក្នុងភូមិភាគភ្នំពេញយើង មានបងប្អូនប្រហែល២០០នាក់ដែលនឹងទទួលជីវិតថ្មី ដែលណែនាំឲ្យគេទាំងអស់គ្នាទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ឲ្យគេមានអំណរសប្បាយ ហើយគេអាចស្រែកខ្លាំងៗថា៖ "អប្បា! ឱព្រះបិតាអើយ!"។ ពេលយើងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ពេលនោះយើងបង្កើតទំនាក់ទំនងថ្មីជាមួយព្រះអង្គដែលជាព្រះបិតា ដែលជាឪពុករបស់យើង។

យប់នេះយើងក៏កំពុងគោរព "ឆ្នាំនៃជំនឿ" ដែរដូច្នេះយើងត្រូវនឹកទៅដល់អ្វីដែលសំខាន់ជាងគេ ដែលជាថ្មដានៃជំនឿរបស់យើង គឺជាព្រះយេស៊ូដែលសោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញ។ បងប្អូនជាទីស្រឡាញ់ តើបងប្អូនចង់ធ្វើជាសាវ័ករបស់ព្រះយេស៊ូគ្រីស្ដ ដែលសោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញឬទេ? តើបងប្អូនចង់ចូលរួមយ៉ាងសកម្ម នៅក្នុងការប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ឬទេ? តើបងប្អូនចង់ធ្វើជាសាក្សីនៃសេចក្ដីសុខសាន្ត និងសេចក្ដីស្រឡាញ់ដើម្បីឲ្យមានយុត្តិធម៌ និងសេចក្ដីពិតនៅក្នុងពិភពលោកនេះឬទេ?។ ហេតុនេះដើម្បីឲ្យយើងជោគជ័យ ខ្ញុំមានបួនចំណុចសំខាន់ៗ៖ ចំណុចទីមួយគឺ "ជួបជាមួយព្រះយេស៊ូផ្ទាល់"។

ជីវិតរបស់យើង គឺយើងធ្វើដំណើររួមជាមួយព្រះយេស៊ូ។ ដោយសារយើងបានជួបព្រះយេស៊ូនៅក្នុងជីវិតរបស់យើង នោះយើងអាចនិយាយបានថា មិនមែនខ្ញុំដែលនៅរស់ គឺជាព្រះយេស៊ូគ្រីស្ដទេដែលរស់នៅក្នុងខ្ញុំ។ ពេលយើងបានជួបព្រះយេស៊ូ ជីវិតរបស់យើងទៅជាជីវិតថ្មី ចំពោះបងប្អូនបេក្ខជនដែលបានធ្វើពិធីជម្រះចិត្តគំនិត នោះបងប្អូនអាចនឹកឃើញដល់ស្ត្រីសាម៉ារីដែលបានជួបព្រះយេស៊ូហើយ នាងក៏ចេញទៅប្រាប់ដល់បងប្អូនឯទៀតៗ នាងជាស្ត្រីថ្មី។ លោកឡាសាបានទទួលជីវិតថ្មី រីឯអ្នកខ្វាក់ភ្នែកក៏បានទទួលជីវិតថ្មីដែរ។ ជីវិតថ្មីនេះ មានឥទ្ធិពលលើជីវិតរបស់យើងផ្ទាល់ ដែលគ្រប់ទុក្ខលំបាក ភាពងងឹត ការភ័យខ្លាចដែលយើងមានសព្វថ្ងៃទៅជាសេចក្ដីសង្ឃឹមវិញ។ យើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង យើងទទួលជីវិតថ្មី ហើយយើងទៅមុខជាមួយព្រះអង្គ។ ហេតុនេះ សូមបងប្អូនយកពេលវេលាដើម្បីស្ដាប់ព្រះយេស៊ូ និងសម្លឹងឆ្ពោះទៅរកព្រះអង្គផង។

ចំណុចទីពីរគឺ "ឲ្យយើងមានចិត្តដើម្បីប្រកាសដំណឹងល្អ"។ សន្ដ:ប៉ូលធ្លាប់មានប្រសាសន៍ថា "ខ្ញុំស្អប់មនុស្សដែលខ្សោយនៅក្នុងការប្រកាសដំណឹងល្អ"។ ផ្ទុយទៅវិញ លោកសូមឲ្យយើងមានសេចក្ដីស្រឡាញ់ពេញខ្លួន ជាពិសេសឲ្យយើងស្រឡាញ់ការប្រកាសដំណឹងល្អ ដែលយើងត្រូវប្រកាស។

មានបងប្អូនដែលនឹងទទួលជីវិតថ្មីប្រាប់ខ្ញុំថា គេចង់ធ្វើជាសាវ័ករបស់ព្រះយេស៊ូពិតមែន ខ្លះថាចង់ប្រកាសដំណឹងល្អ តែសូមឲ្យច្បាស់អំពីរបៀបដែលយើងធ្វើ គឺសូមឲ្យយើងធ្វើដោយចេញពីចិត្តរបស់ខ្លួនពិតមែន ឲ្យចេញពីសេចក្ដីស្រឡាញ់របស់ខ្លួនពិតមែន ដើម្បីឲ្យព្រះនាមរបស់ព្រះយេស៊ូ ទៅជានាមដែលណែនាំឲ្យមនុស្សទាំងអស់មានអំណរសប្បាយយ៉ាងពិតប្រាកដ។

សូមធ្វើនៅតាមកន្លែងដែលយើងរៀន ដែលយើងធ្វើការ ដែលយើងរស់នៅសព្វថ្ងៃ គឺយើងត្រូវយកចិត្តទុកដាក់ប្រកាសដោយសេចក្ដីស្រឡាញ់អស់ពីដួងចិត្តអស់ពីជំនឿអស់ពីកម្លាំងកាយ យើងប្រកាសដំណឹងល្អដែលជាទ្រព្យសម្បត្តិរបស់យើង ប្រកាសអ្វីៗដែលល្អជាងគេនៅក្នុងដួងចិត្តរបស់យើង ប្រកាសនូវសេចក្ដីស្រឡាញ់ដែលយើងមាន យើងប្រកាសដោយសារធម៌មេត្តាករុណារបស់ព្រះយេស៊ូជំរុញយើង។

បើយើងជឿថានេះជាដំណឹងល្អ យើងត្រូវតែប្រកាសឲ្យបងប្អូនឯទៀតៗបានទទួលដំណឹងល្អនេះដែរ។ នៅក្នុងទូរទស្សន៍ ជួនកាលយើងឃើញគេផ្សាយអំពីសង្គ្រាម អំពីមនុស្សដែលអស់សង្ឃឹម ពួកគេគួរឲ្យអាណិតណាស់ ដូច្នេះសូមឲ្យយើងភ្ញាក់ស្មារតីចំពោះមនុស្សដែលនៅជុំវិញយើង តើមានប៉ុន្មាននាក់ដែលមិនមានអាហារបរិភោគ គ្មានលុយទៅពេទ្យ គ្មានអង្ករមួយកំប៉ុងសម្រាប់ដាំឲ្យកូនហូប សូមកុំឲ្យយើងភ្លេចរឿងនេះ។ ដោយសារសេចក្ដីស្រឡាញ់ដែលយើងបានទទួលពីព្រះយេស៊ូ សូមឲ្យយើងចេញពីផ្ទះរបស់យើង ទៅចែករំលែកអ្វីៗដែលយើងមានដល់បងប្អូនឯទៀតៗកុំបីខានឡើយ។

ចំណុចទីបីគឺ "យើងទាំងអស់គ្នាត្រូវតែប្រមូលកម្លាំងរបស់យើង ដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់កើតឡើងនៅលើផែនដីនេះ"។ តើយើងធ្វើដូចម្ដេច ដើម្បីឲ្យសេចក្ដីស្រឡាញ់និងសេចក្ដីសុខជួបជុំគ្នា ឲ្យយុត្តិធម៌និងសេចក្ដីពិតកើតមាន ដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់កើតឡើងយ៉ាងពិតប្រាកដមែន។ ប្រសិនបើគ្មានយើង ព្រះជាម្ចាស់ក៏ធ្វើមិនបានដែរ ហើយព្រះរាជ្យរបស់ព្រះអង្គលើផែនដីនេះក៏គ្មាន។ ហេតុនេះ គឺគ្រប់ពេលវេលាឲ្យយើងជ្រើសរើសសេចក្ដីស្រឡាញ់ជាអាទិភាព គឺសេចក្ដីស្រឡាញ់សម្រាប់មនុស្សទាំងអស់ ឲ្យបេះដូងរបស់យើងទៅជាបេះដូងមួយយ៉ាងធំដែលអាចទទួលមនុស្សទាំងអស់ឲ្យនៅពីខាងក្នុងបាន ដូចមេមាន់ទទួលកូនទាំងប៉ុន្មានរបស់វានៅក្នុងស្លាប។ ឲ្យយើងបើកបេះដូងរបស់យើងទៅក្នុងសេចក្ដីស្រឡាញ់ ដើម្បីបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ។

យើងដឹងថា មនុស្សទាំងអស់មានឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់ស្មើៗគ្នា មានកិត្តិយសស្មើៗគ្នា ដោយសារយើងមានលក្ខណៈដូចព្រះជាម្ចាស់ដូចៗគ្នា។ តែយើងក៏ដឹងដែរថា ទោះបីយើងមានឋានៈស្មើគ្នាប៉ុន្តែនៅក្នុងសង្គមរបស់យើង មានអយុត្តិធម៌ក៏ច្រើនដែរ ដូចយើងឃើញស្រាប់ សព្វថ្ងៃមានគេសាងសង់ផ្ទះវីឡា ផ្ទះបុរីច្រើនណាស់ដែលមានតម្លៃខ្ពស់ តែនៅក្បែរនោះក៏មានខ្ទមអ្នកក្រីក្រដ៏កំពូលដែរ។ នេះជាអ្វីដែលធ្វើឲ្យសង្គមរបស់យើង ឬយើងផ្ទាល់ឈឺចិត្ត ដូច្នេះយើងត្រូវធ្វើដូចម្ដេច ឲ្យយើងទៅជាក្រុមគ្រួសារមួយដែលចេះសហការគ្នា ដើម្បីដោះស្រាយបញ្ហា ក្នុងគោលបំណងកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ឲ្យបាន។

នៅក្នុងព្រះសហគមន៍យើង មានក្រុមជាច្រើនដែលយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត ក្នុងការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ថ្ងៃនេះ មានបងប្អូនប៉ុន្មាននាក់មកពីកំពង់ស្ពឺរួមជាមួយអ្នកដឹកនាំ នេះជាសញ្ញាសម្គាល់មួយពិសេសអំពីសេចក្ដីស្រឡាញ់ ដែលណែនាំឲ្យយើងខិតខំកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់តទៅទៀត។

ចំណុចទីបួន គឺឲ្យយើងនឹកឃើញដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ "ដូចខ្ញុំ ព្រះបិតា ព្រះវិញ្ញាណដ៏វិសុទ្ធជាធ្លុងតែមួយយ៉ាងណា សូមឲ្យបងប្អូនទាំងអស់គ្នាទៅជាធ្លុងតែមួយយ៉ាងនោះដែរ"។ យើងទាំងអស់គ្នា មកពីប្រទេសដែលមានវប្បធម៌ផ្សេងគ្នា មានកម្រិតសិក្សាផ្សេងគ្នា ប៉ុន្តែនៅក្នុងព្រះយេស៊ូ យើងជាក្រុមគ្រួសារតែមួយ។ យើងជាព្រះសហគមន៍កាតូលិក យើងត្រូវធ្វើជាសញ្ញាសម្គាល់នៃជីវិតជាធ្លុងតែមួយដូចព្រះជាម្ចាស់ដែលជាព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធ ដោយឲ្យយើងយកចិត្តទុកដាក់នឹងគ្នាទៅវិញទៅមក ទោះបីយើងជាមនុស្សផ្សេងគ្នាក៏ដោយ នេះជាមូលដ្ឋានគ្រឹះ ដើម្បីកសាងពិភពលោកថ្មីដែលមនុស្សទាំងអស់កំពុងរង់ចាំ។

សូមឲ្យយើងមានអំណរសប្បាយ ដូចព្រះយេស៊ូបានអធិដ្ឋានថា ៖ "ឲ្យអំណរសប្បាយរបស់យើងទៅជាអំណរសប្បាយពេញលក្ខណៈ" អំណរសប្បាយដែលព្រះយេស៊ូប្រទានឲ្យយើង ជាអំណរសប្បាយដែលនៅខាងក្នុងមើលមិនឃើញ ជាអំណរសប្បាយដែលណែនាំឲ្យយើងចេះតស៊ូ ណែនាំឲ្យយើងទៅជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ។ មានបុរសម្នាក់ដែលពីមុនធ្លាប់ស្អប់គ្រីស្តបរិស័ទ ស្អប់ព្រះជាម្ចាស់ដល់កំពូល បាននិយាយថា ៖ "នៅថ្ងៃដែលខ្ញុំឃើញគ្រីស្តបរិស័ទចេញពីព្រះវិហារ ដោយមានអំណរសប្បាយយ៉ាងពិតប្រាកដ គឺថ្ងៃនោះហើយ ដែលនាំឲ្យខ្ញុំជឿលើព្រះជាម្ចាស់ដូចពួកគាត់ដែរ"។

ដូច្នេះ តើធ្វើដូចម្ដេចដើម្បីឲ្យមនុស្សលោកមានជំនឿលើព្រះជាម្ចាស់ ដោយសារបានឃើញយើងមានអំណរសប្បាយយ៉ាងពិតប្រាកដមែននោះ?។ អាស្រ័យហេតុនេះ យើងជាគ្រីស្តទូត ជាសាវ័ករបស់ព្រះយេស៊ូ នៅយប់នេះ យើងត្រូវតែមានអំណរ យើងត្រូវតែមានសេចក្ដីសុខ ដ្បិតយើងដឹងថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញយ៉ាងពិតប្រាកដមែន ហើយព្រះអង្គគង់នៅជាមួយយើងទាំងអស់គ្នាទៀតផង។

អាលេលូយ៉ា! ។ អាម៉ែន។

# អធិដ្ឋានតេហ្សេសំរាប់បីភូមិភាគ



ព្រះសហគមន៍គីរីវង្ស បានរៀបចំពិធីអធិដ្ឋានតេហ្សេសម្រាប់ភូមិភាគទាំងបី កាលពីថ្ងៃទី៤-៦ ខែមេសាកន្លងទៅដោយមានការណែនាំពីបងប្រុសមកពីសហគមន៍តេហ្សេនៃប្រទេសបារាំង និងមានការចូលរួមដោយយុវជនប្រមាណ៧០នាក់។

បងប្រុស អង់ដ្រេអាស (Andreas) មកពីភូមិតេហ្សេបានមានប្រសាសន៍ឲ្យដឹងថា កម្មវិធីនេះធ្វើឡើង ដើម្បីឲ្យបងប្អូនទាំងអស់គ្នាយល់ពីអត្ថន័យនៃការអធិដ្ឋានតេហ្សេ និងចង់ឲ្យបងប្អូនមានទំនាក់ទំនងជាមួយព្រះយេស៊ូកាន់តែជិតស្និទ្ធថែមទៀត។ ម្យ៉ាងវិញទៀត គ្រីស្តបរិស័ទខ្មែរមួយចំនួនធំមិនធ្លាប់បានចូលរួមកម្មវិធីតេហ្សេ និងដឹងពីរបៀបនៃការអធិដ្ឋាននេះនៅឡើយ។

បងប្រុសបន្តថា ការអធិដ្ឋានតេហ្សេគឺជាការស្ងៀមស្ងាត់ដើម្បីសន្ទនាជាមួយព្រះជាម្ចាស់ ដែលធ្វើឲ្យយើងអាចយល់ពីសេចក្តីស្រឡាញ់របស់ព្រះម្ចាស់បានច្រើនជាងមុន។

សហគមន៍តេហ្សេ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៤៤ ដោយបងប្រុស រ៉ូហ្សេរ ជនជាតិបារាំង។ សព្វថ្ងៃនេះ សហគមន៍នេះបានក្លាយជាកន្លែងអធិដ្ឋានមួយដ៏ពេញនិយមសម្រាប់គ្រីស្តបរិស័ទនៅទូទាំងសកលលោក និងដល់អស់អ្នកដែលចង់ស្វែងរកសន្តិភាពផ្លូវចិត្ត ដោយការអធិដ្ឋាននិងនៅស្ងៀមស្ងាត់។

## A Taize Retreat for the Youth of the Three Dioceses

Last April 4th to 6th, two brothers from Taizé community (France) led a retreat at Kiri Vong church in which 70 young people joined.

Brother Andreas said : “We proposed this program to have youth understand the meaning of Taizé prayer and how to communicate and make relationship with God. On the other hand, a large number of Catholics in Cambodia cannot have the occasion to go to Taizé in France.

Brother Andreas explained noted that Taizé prayer is a time of silence in which we converse with God. It helps us to understand the love of God deeper than before.

Taizé Community was established in 1944 by Brother Roger, a French man. The Community today has become a popular place for Christian all around the world, especially for those who want to find mental peace by prayer and silence.

## សកម្មភាពលោក សុខកុមារ អូលីវីយេ ឆ្មឹតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្នុងខែ មេសា ឆ្នាំ២០១៣

៤ មេសា ៖ អធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅនៅកំពត
៥-៦ មេសា ៖ ចូលរួមសំណាក់ធម៌តេហ្សេនៅគីរីវង្ស
៧ មេសា ៖ អភិបូជានៅព្រះសហគន៍ថ្មីព្រៃកប្បាស
៨ មេសា ៖ ចូលរួមព្រឹត្តិការណ៍ប្រកួតកីឡានៅតាកែវ
៩ មេសា ៖ ជួយគ្រួសារក្រីក្រនៅទីក្រុងតាកែវ
ពិធីចូលឆ្នាំខ្មែរនៅវិទ្យាស្ថានសន្តប៉ូល
១០-១១ មេសា ៖ ចូលរួមបោះជំរុំកាយរិទ្ធនៅគីរីវង្ស
១៣ មេសា ៖ អភិបូជាចូលឆ្នាំថ្មីនៅព្រះវិហារសន្តយ៉ូសែបផ្សារតូច
១៤ មេសា ៖ អភិបូជាចូលឆ្នាំថ្មីនៅតាកែវ
១៥ មេសា ៖ ចូលឆ្នាំថ្មី
១៦ មេសា ៖ ពិធីបុណ្យអភិបូជានៅព្រះសហគមន៍អរិយ៍ក្សត្រ សម្រាប់ព្រះនាងម៉ារីនៃទន្លេមេគង្គ
១៧ មេសា ៖ ប្រជុំជាមួយលោកអភិបាល និងក្រុមប្រឹក្សាទាំងបីភូមិភាគ
១៩ មេសា ៖ ប្រជុំជាមួយអ្នកសម្របសម្រួលសាលាមត្តេយ្យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
បង្រៀននៅសាលាអប់រំជំនឿគ្រីស្តបរិស័ទសន្តយ៉ូស្ទីន
២០ មេសា ៖ បង្រៀនទេវវិទ្យានៅសាលាអប់រំជំនឿគ្រីស្តបរិស័ទសន្តយ៉ូស្ទីន
២១ មេសា ៖ អគ្គសញ្ញាលាបថ្វាសនៅព្រះវិហារបឹងទំពុន
២២ មេសា ៖ ប្រជុំជាមួយលោកគ្រូអ្នកគ្រូនៃវិទ្យាល័យសន្តហ្វ្រង់ស្វ័រ តាកែវ
២៣ មេសា ៖ សំណាក់ធម៌ជាមួយក្រុមបូជាចារ្យ
ប្រសិទ្ធពរលើមណ្ឌលសុខភាពថ្មីនៃសន្តលូកា
ប្រជុំជាមួយលោកគ្រូអ្នកគ្រូនៃសាលាអប់រំគ្រីស្តបរិស័ទសន្តយ៉ូស្ទីន
អភិបូជានៅទេវវិទ្យាល័យ
២៤ មេសា ៖ ប្រសិទ្ធពរលើបឋមសិលានៅមណ្ឌលដុនបូស្កូបងស្រី
២៥ មេសា ៖ ស្វាគមន៍ធាតុសន្តីថេរេសា
២៦ មេសា ៖ ស្វាគមន៍ធាតុសន្តីថេរេសានៅជ្រៃធំ
២៧ មេសា ៖ ទិវានៃការត្រាស់ហៅ-ស្វាគមន៍ធាតុសន្តីថេរេសានៅព្រះវិហារសន្តយ៉ូសែប និងព្រះវិហារបឹងទំពុន
២៩ មេសា ៖ ស្វាគមន៍ធាតុសន្តីថេរេសានៅមណ្ឌលសកម្មភាពមេគង្គ
៣០ មេសា ៖ ស្វាគមន៍ធាតុសន្តីថេរេសានៅមណ្ឌលសកម្មភាពកំពង់សោម

## Activities of Bishop Olivier Schmitthaeusler, MEP Apostolic Vicar of Phnom Penh, April 2013

4 April : Night Prayer for Vocations at Kampot
5-6 April : Join Taize Retreat at Kirivong
7 April : Mass at new parish of PREY KBAS
8 April : SPORTS EVENT at Takeo
9 April : Help poor families at Takeo City
Khmer New Year at Saint Paul
10 -11 April : Join Scouts Camp at Kirivong
13 April : Khmer New Year Mass at St Joseph
14 April : Khmer New Year Mass at St Takeo
15 April : Khmer New Year
16 April : Celebration at AREYKSAT for our LADY of MEKONG
17 April : Meeting with Bishops and General Vicars
19 April : Meeting with Kindergartens Coordinators
Teach at St Justin School
20 April : Teach Theology at St Justin School
21 April : Confirmation at Boeung Toumpun
22 April : Meeting with teachers at St Francis High School
23 April : Recollection for all Priests
Blessing of the New Shelter ST LUKE
Meeting with St Justin School Teachers
Mass at Major Seminary
24 April : Don Bosco Salesian Sisters break ground blessing
25 April : Welcome of the Relics of St TERESA
26 April : at Chrey THOM with the relics
27 -28 April : at Chrey THOM with the relics
: Vocation Day – Relics at St Jospeh and Boeung Toumpun
29 April : Relics at Mekong Sector
30 April : Relics at Kompong SOM

# ឆ្នាំនៃជំនឿ រួមរស់ជាព្រះសហគមន៍

## សកម្មភាពរបស់លោកអភិបាលប្រចាំខែ



អេម៉ាណូអែល សំឡេងព្រះសហគមន៍កាតូលិក
រាល់ថ្ងៃសុក្រ ម៉ោង ២:០០ - ៣:០០ រសៀល
វិទ្យុ FM 102.5Mhz

កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"
រាល់ថ្ងៃអង្គារ៍ ម៉ោង ១០:០០ - ១១:០០ ព្រឹក
វិទ្យុ FM 99.5Mhz


APOSTOLIC VICARIATE PHNOM PENH

Chairman: Msgr. Olivier Schmitthaeusler

អ្នកទទួលខុសត្រូវៈ លោកអភិបាល អូលីវីយេ ឆ្មីតអឺស្លែរ

Tell: 023 64 00 841

Email: apostolicvicariate.phnompenh@gmail.com

#25, St242, Boeung Prolit, 7Makara, Phnom Penh.